00932645

E284/2/1/2

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/date de reception): 26 / 06 / 2013
ម៉ោង (Time/Heure) : 15:40
មន្ត្រីទទួលបន្ទុកសំណុំរឿង /Case File Officer/L'agent chargé du dossier: SANN RADA

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

---

អង្គជំនុំជម្រះតុលាការកំពូល
Supreme Court Chamber
Chambre de la Cour suprême

សំណុំរឿងលេខ: ០០២/១៩-០៩-២០០៧-អ.វ.ត.ក-អ.ជ.ស.ដ/អ.ជ.ត.ក(២៦)

Case File/Dossier N°. 002/19-09-2007-ECCC-TC/SC(26)

**នៅចំពោះមុខ៖**

**ចៅក្រម គង់ ស្រីម ប្រធាន**
**ចៅក្រម Chandra Nihal JAYASINGHE**
**ចៅក្រម Agniezska KLONOWIECKAMILART**
**ចៅក្រម ម៉ុង មុនីចរិយា**
**ចៅក្រម Florence Ndepele Mwachande MUMBA**
**ចៅក្រម សោម សិរីវឌ្ឍ**
**ចៅក្រម យ៉ា ណារិន**

**កាលបរិច្ឆេទឯកសារ៖** **ថ្ងៃទី ២៦ ខែ មិថុនា ឆ្នាំ ២០១៣**
**ភាសាដើម៖** **ខ្មែរ/អង់គ្លេស**
**ចំណាត់ថ្នាក់ឯកសារ៖** **សាធារណៈ:**

---

# សេចក្តីសម្រេចលើសំណើរបស់សហព្រះរាជអាជ្ញាសុំការបញ្ជាក់បំភ្លឺ

---

**សហព្រះរាជអាជ្ញា**

ជា លាង
Andrew CAYLEY

**ជនជាប់ចោទ**

ខៀវ សំផន

នួន ជា

**សហមេធាវីជនជាប់ចោទ នួន ជា**

សុន អរុណ
Victor KOPPE

**សហមេធាវីជនជាប់ចោទ ខៀវ សំផន**

គង់ សំអុន
Anta GUISSÉ
Arthur VERCKEN
Jacques VERGÈS

សំណុំរឿងលេខ: ០០២/១៩-០៩-២០០៧-អ.វ.ត.ក-អ.ជ.ស.ដ/អ.ជ.ត.ក(២៦)

ឯកសារលេខ E284/2/1/2

**<u>សហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី</u>**

**ពេជ អង្គ**

Elisabeth SIMONNEAU FORT

1. **អង្គជំនុំជម្រះតុលាការកំពូល** (អ.ជ.ត.ក) នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (អ.វ.ត.ក) បង្កើតឡើងដើម្បីកាត់សេចក្ដីឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃរបបកម្ពុជាប្រជាធិបតេយ្យរវាងថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ១៩៧៥ ដល់ ថ្ងៃទី ៦ ខែ មករា ឆ្នាំ ១៩៧៩ បានទទួលសំណើដែលត្រូវបានដាក់ជូននៅថ្ងៃទី ៦ ខែ មិថុនា ឆ្នាំ ២០១៣ ដោយសហព្រះរាជអាជ្ញាស្នើអង្គជំនុំជម្រះតុលាការកំពូល ផ្ដល់សេចក្ដីណែនាំទាក់ទងនឹងអំណាចរបស់ខ្លួនក្នុងការបង្គាប់ឱ្យអង្គជំនុំជម្រះសាលាដំបូងបើកឡើងវិញ នូវសវនាការលើភស្តុតាងបន្ទាប់ពីបិទសវនាការ (“សំណើ”)[1]។

2. នៅថ្ងៃទី ២៦ ខែ មេសា ឆ្នាំ ២០១៣ អង្គជំនុំជម្រះសាលាដំបូង បានចេញ “សេចក្ដីសម្រេចលើការបំបែកកិច្ចដំណើរការនីតិវិធីនៅក្នុងសំណុំរឿង ០០២ បន្ទាប់ពីមានសេចក្ដីសម្រេចរបស់អង្គជំនុំជម្រះតុលាការកំពូល ចុះថ្ងៃទី ៨ ខែ កុម្ភៈ ឆ្នាំ ២០១៣”[2] (“សេចក្ដីសម្រេចលើកទីពីរលើការបំបែកសំណុំរឿង) ក្នុងនោះ អង្គជំនុំជម្រះសាលាដំបូងបានបំបែកកិច្ចដំណើរការនីតិវិធីក្នុងសំណុំរឿង ០០២ ម្ដងទៀតទៅជាការជំនុំជម្រះដោយផ្នែក ហើយបានកំណត់វិសាលភាពនៃការជំនុំជម្រះលើកទីមួយនៅត្រឹមអង្គហេតុចោទប្រកាន់ និងបទចោទប្រកាន់មួយចំនួន (“សំណុំរឿង ០០២/០១”) បន្ទាប់ពីអង្គជំនុំជម្រះតុលាការកំពូលបានលុបចោលសេចក្ដីសម្រេចពីមុនរបស់អង្គជំនុំជម្រះសាលាដំបូងលើការបំបែកកិច្ចដំណើរការនីតិវិធី។ នៅថ្ងៃទី ១០ និង ២៧ ខែ ឧសភា ឆ្នាំ ២០១៣ សហព្រះរាជអាជ្ញា និង នួន ជា បានប្ដឹងសាទុក្ខនឹងសេចក្ដីសម្រេចលើកទីពីរលើការបំបែកកិច្ចដំណើរការនីតិវិធី (“បណ្ដឹងសាទុក្ខភ្លាមៗរបស់សហព្រះរាជអាជ្ញា” និង“បណ្ដឹងសាទុក្ខភ្លាមៗរបស់នួនជា”)[3]។ នៅក្នុងបណ្ដឹងសាទុក្ខភ្លាមៗ សហព្រះរាជអាជ្ញាស្នើសុំឱ្យធ្វើវិសោធនកម្មទៅលើសេចក្ដីសម្រេចលើកទីពីរលើការបំបែកកិច្ចដំណើរការនីតិវិធី ដោយពង្រីកវិសាលភាពសំណុំរឿង ០០២/០១ ដើម្បី

---

[1] សំណើរបស់សហព្រះរាជអាជ្ញាសុំការបញ្ជាក់បំភ្លឺពីអំណាចរបស់អង្គជំនុំជម្រះតុលាការកំពូល ក្នុងការបើកឡើងវិញនូវកិច្ចដំណើរការនីតិវិធីលើភស្តុតាងនៅក្នុងពេលណាមួយមុនពេលចេញសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង ក្នុងសំណុំរឿង ០០២/០១ ឯកសារ E284/2/1/1 ចុះថ្ងៃទី ៦ ខែ មិថុនា ឆ្នាំ ២០១៣។ គ្មានការឆ្លើយតបទៅនឹងសំណើនេះត្រូវបានដាក់ឡើយ។

[2] ឯកសារ E284។

[3] បណ្ដឹងសាទុក្ខភ្លាមៗរបស់សហព្រះរាជអាជ្ញា ប្រឆាំងនឹងសេចក្ដីសម្រេចលើកទីពីរស្ដីពីការបំបែកកិច្ចដំណើរការនីតិវិធីនៃសំណុំរឿង ០០២ ឯកសារ E284/2/1 ចុះថ្ងៃទី ១០ ខែ ឧសភា ឆ្នាំ ២០១៣។ បណ្ដឹងសាទុក្ខភ្លាមៗជំទាស់នឹងសេចក្ដីសម្រេចលើកទីពីររបស់អង្គជំនុំជម្រះសាលាដំបូងស្ដីពីការបំបែកកិច្ចដំណើរការនីតិវិធី និងសារណាតបចំពោះបណ្ដឹងសាទុក្ខរបស់សហព្រះរាជអាជ្ញាជំទាស់នឹងសេចក្ដីសម្រេចលើកទីពីរលើការបំបែកកិច្ចដំណើរការនីតិវិធី ឯកសារ E284/1 ចុះថ្ងៃទី ២៧ ខែ ឧសភា ឆ្នាំ ២០១៣។

00932648



បញ្ចូលមន្ទីរសន្តិសុខ ស-២១[4] ចំណែកឯ នួន ជា ស្នើសុំឱ្យលុបចោលសេចក្តីសម្រេចលើកទីពីរលើការបំបែកកិច្ចដំណើរការនីតិវិធី ដោយមានផលប៉ះពាល់ដល់ សាលដីកានាពេលអនាគតលើការបំបែកកិច្ចដំណើរការនីតិវិធី បើមិនអញ្ចឹងទេ ស្នើសុំឱ្យពង្រីកវិសាលភាពសំណុំរឿង ០០២/០១វិញ ដើម្បីបញ្ចូលបទចោទប្រកាន់ប្រល័យពូជសាសន៍ និងបទចោទប្រកាន់ទាំងឡាយទាក់ទងនឹងឧក្រិដ្ឋកម្មដែលត្រូវបានចោទប្រកាន់ថាបានប្រព្រឹត្តឡើងនៅសហករណ៍ និងការដ្ឋានការងារ[5]។

3. នៅថ្ងៃទី ៣១ ខែ ឧសភា ឆ្នាំ ២០១៣ អង្គជំនុំជម្រះសាលាដំបូង បានប្រកាសថា ការជំនុំជម្រះនៅក្នុងសំណុំរឿង ០០២/០១ កំពុងតែចូលដល់ដំណាក់កាលចុងក្រោយ ហើយ "ដើម្បីធានាបានការបញ្ចប់ទាន់ពេលវេលានៃសាលក្រមសម្រាប់សំណុំរឿង ០០២/០១ និងអនុលោមតាមវិធាន ១០៤(៤) នៃវិធានផ្ទៃក្នុង អង្គជំនុំជម្រះនឹងពុំពន្យារពេលការបញ្ចប់កិច្ចដំណើរការនីតិវិធីដេញដោលលើភ័ស្តុតាងក្នុងសំណុំរឿង ០០២/០១ ដោយរង់ចាំសេចក្តីសម្រេចលើបណ្តឹងសាទុក្ខរបស់សហព្រះរាជអាជ្ញាជំទាស់នឹងសេចក្តីសម្រេចបំបែកកិច្ចដំណើរការនីតិវិធីសវនាការជាថ្មីឡើយ (ឯកសារ 284) លើកលែងតែមានការបង្គាប់ដូច្នេះពីសំណាក់អង្គជំនុំជម្រះតុលាការកំពូល"[6] ("អនុស្សរណៈរបស់អង្គជំនុំជម្រះសាលាដំបូង")។

4. នៅក្នុងសំណើ សហព្រះរាជអាជ្ញាស្នើសុំអង្គជំនុំជម្រះតុលាការកំពូលបញ្ជាក់ឱ្យច្បាស់ថា ប្រសិនបើសវនាការលើភ័ស្តុតាងក្នុងសំណុំរឿង ០០២/០១ ចប់មុនពេលដែលអង្គជំនុំជម្រះតុលាការកំពូលបានចេញសេចក្តីសម្រេចលើបណ្តឹងសាទុក្ខភ្លាមៗនោះ "អង្គជំនុំជម្រះតុលាការកំពូលមានសិទ្ធិអំណាចក្នុងការចេញដីកាសម្រេចបង្គាប់ឱ្យ អង្គជំនុំជម្រះសាលាដំបូង បើកធ្វើសវនាការដេញដោលលើភ័ស្តុតាងជាថ្មីឡើងវិញ ប្រសិនបើអង្គជំនុំជម្រះនេះសម្រេចថាឱ្យពង្រីកវិសាលភាពនៃការជំនុំជម្រះក្តី"[7]។ សហព្រះរាជអាជ្ញា ក៏ស្នើសុំឱ្យ អង្គជំនុំជម្រះតុលាការកំពូល បញ្ជាក់ឱ្យបានច្បាស់ថា "ការបើកសវនាការដេញដោលលើភ័ស្តុតាងសាជាថ្មីឡើងវិញនេះ អាចត្រូវបង្គាប់ឱ្យធ្វើនៅពេល

---

[4] បណ្តឹងសាទុក្ខភ្លាមៗរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ៨៤ ។

[5] បណ្តឹងសាទុក្ខភ្លាមៗរបស់ នួន ជា កថាខណ្ឌ ៨៤ ។

[6] អនុស្សរណៈរបស់ចៅក្រម និល ណុន ប្រធានអង្គជំនុំជម្រះសាលាដំបូង ចំណងជើង "ការជូនដំណឹងអំពីសវនាការដែលនៅសេសសល់មុនពេលបិទកិច្ចដំណើរការនីតិវិធីសវនាការលើភ័ស្តុតាងនៅក្នុងសំណុំរឿង ០០២/០១ និងការកំណត់កាលបរិច្ឆេទនៃកិច្ចប្រជុំរៀបចំសវនាការលើកចុងក្រោយសម្រាប់ថ្ងៃទី ១៣ ខែ មិថុនា ឆ្នាំ ២០១៣" ឯកសារ E288 ចំណាត់ថ្នាក់សម្ងាត់ដាក់នៅថ្ងៃទី ៣១ ខែ ឧសភា ឆ្នាំ ២០១៣ និងចំណាត់ថ្នាក់សាធារណៈ ដោយមានការកោសលុប ដាក់ថ្ងៃទី ៥ ខែ មិថុនា ឆ្នាំ ២០១៣ កថាខណ្ឌ ១០។

[7] សំណើ កថាខណ្ឌ ៦ ។

ណាក៏បាន នៅមុនពេលអង្គជំនុំជម្រះសាលាដំបូង ចេញសាលក្រមស្ថាពរនៅក្នុងសំណុំរឿង ០០២/០១”[8]។

5. ជាបឋម អង្គជំនុំជម្រះតុលាការកំពូលកត់សម្គាល់ថា សហព្រះរាជអាជ្ញាស្នើសុំអង្គជំនុំជម្រះតុលាការកំពូលឱ្យផ្តល់ការបញ្ជាក់បំភ្លឺទៅលើបញ្ហាផ្លូវច្បាប់ ដែលទាក់ទងនឹងអំណាចរបស់អង្គជំនុំជម្រះតុលាការកំពូល។ គ្មានបទប្បញ្ញត្តិច្បាស់លាស់ណាមួយនៅក្នុងកម្រងឯកសារច្បាប់របស់ អ.វ.ត.ក ដែលបញ្ជាក់ពីសមត្ថកិច្ចរបស់អង្គជំនុំជម្រះតុលាការកំពូល ក្នុងការផ្តល់ការបញ្ជាក់បំភ្លឺបែបនោះឡើយ[9]។ ទោះបីយ៉ាងណា អង្គជំនុំជម្រះតុលាការកំពូលរំឭកថា “ដំណើរការប្រហាក់ប្រហែលគ្នាសម្រាប់ការបំភ្លឺ ឬការកំណត់ជាក់លាក់ស្តីពីបញ្ហាច្បាប់ គឺមានជាទូទៅនៅកម្រិតអន្តរជាតិ [ហើយ] ផ្អែកតាមមូលដ្ឋាននេះ អង្គជំនុំជម្រះតុលាការកំពូលពិចារណាឃើញថា នៅពេលដែលផលប្រយោជន៍យុត្តិធម៌តម្រូវឱ្យធ្វើដូច្នេះ អង្គជំនុំជម្រះអាចនឹងទទួលយកសំណើសុំការណែនាំខាងផ្លូវច្បាប់”[10]។ សំណើសុំការបញ្ជាក់បំភ្លឺ ឬការណែនាំខាងផ្លូវច្បាប់ អាចចេញពីអង្គភាពណាមួយរបស់តុលាការ ឬភាគីណាមួយនៅក្នុងកិច្ចដំណើរការនីតិវិធី[11]។ ដូច្នេះ អង្គជំនុំជម្រះ

---

[8]សំណើ កថាខណ្ឌ ៦ ។

[9] អង្គជំនុំជម្រះតុលាការកំពូលកត់សម្គាល់ឃើញថា សហព្រះរាជអាជ្ញាពុំបានស្នើសុំការបកស្រាយលើសេចក្តីសម្រេចរបស់តុលាការ ដែលអង្គជំនុំជម្រះតុលាការកំពូល នឹងមានសមត្ថកិច្ចក្នុងការបំភ្លឺអនុលោមតាមមាត្រា ៦០៦(១) នៃក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា។ មាត្រានេះចែងនៅក្នុងផ្នែកពាក់ព័ន្ធថា: “គ្រប់ការលំបាកក្នុងការបកស្រាយសេចក្តីសម្រេចរបស់តុលាការ ត្រូវដាក់ជូនតុលាការដែលបានប្រកាសសេចក្តីសម្រេចនេះពិនិត្យ”។

[10]សេចក្តីសម្រេចលើសំណើរបស់អង្គជំនុំជម្រះសាលាដំបូង និងមេធាវីការពារក្តី អៀង ធីរិទ្ធ សុំការណែនាំ និងការបញ្ជាក់បំភ្លឺ ឯកសារ E 138/1/1 0/1/5/8/2 ចុះថ្ងៃទី ៣១ ខែ ឧសភា ឆ្នាំ ២០១៣ (សេចក្តីសម្រេចលើសំណើរបស់ អៀង ធីរិទ្ធ សុំការបញ្ជាក់បំភ្លឺ” កថាខណ្ឌ ១២។

[11]*សូមមើល* សេចក្តីសម្រេចលើសំណើរបស់អៀង ធីរិទ្ធ សុំការបញ្ជាក់បំភ្លឺ កថាខណ្ឌ ១២ *ដោយយោងទៅលើ* វិធាន ៦៨(ឆ) និង ១៧៦ *ស្ទួន* (ក)នៃវិធានស្តីពីនីតិវិធី និងភស្តុតាងរបស់សាលាក្តីពិសេសសម្រាប់លីបង់(STL) វិធាន៧២ ស្តីពីនីតិវិធី និងភស្តុតាង របស់តុលាការពិសេសសម្រាប់ស៊ីរ៉ាឡេអូន (SCSL) *រឿងក្តី រដ្ឋអាជ្ញា* ទល់នឹង *Thomas Lubanga Dyilo* ការបញ្ជាក់បំភ្លឺ ចុះថ្ងៃទី ១៤ ខែ ឧសភា ឆ្នាំ ២០០៧ សំណុំរឿងលេខ ICC-01/04-01/06-904 (OA 8) *និងក្នុងសំណុំរឿងដែល* ការបញ្ជាក់បំភ្លឺរបស់អង្គជំនុំជម្រះសាលាឧទ្ធរណ៍ ចុះថ្ងៃទី ១៩ ខែ តុលា ឆ្នាំ ២០០៦ សំណុំរឿងលេខ ICC-01/04-01/06-590 (OA 4) រឿងក្តី *រដ្ឋអាជ្ញា ទល់នឹង Dario Kordić and Mario Čerkez* សំណុំរឿងលេខ IT-95-14/2 សេចក្តីសម្រេច លើ សំណើសុំការ បញ្ជាក់បំភ្លឺ ចុះថ្ងៃទី ១៥ ខែ មករា ឆ្នាំ ១៩៩៩ រឿងក្តី*រដ្ឋអាជ្ញា ទល់នឹង Slobodan Milošević* សំណុំរឿងលេខ IT-02-54 សេចក្តីសម្រេចលើសំណើ របស់រដ្ឋអាជ្ញាសុំការបញ្ជាក់បំភ្លឺ ឬក៏សំណើជំនួស ចុះថ្ងៃទី ២៥ ខែ មករា ឆ្នាំ ២០០២ រឿងក្តី *រដ្ឋអាជ្ញា ទល់នឹង Ramush Haradinaj និងអ្នក ផ្សេងទៀត* សំណុំរឿងលេខ IT-04-84 សេចក្តីសម្រេចលើសំណើសុំការ បញ្ជាក់បំភ្លឺអំពីសេចក្តីណែនាំអនុវត្តន៍ស្តីពីនីតិវិធីសម្រាប់ដាក់សារណាជាលាយលក្ខណ៍អក្សរ នៅក្នុងកិច្ចដំណើរការនីតិវិធីបណ្តឹងសាទុក្ខ និងសុំពន្យារពេល ចុះថ្ងៃទី ២២ ខែ វិច្ឆិកា ឆ្នាំ ២០០៥។ ការអនុវត្តច្បាប់ជាទូទៅ ក៏អនុញ្ញាតឱ្យមានបណ្តឹងសាទុក្ខ “តាម

តុលាការកំពូល នឹងពិចារណាថាតើមាន ឬក៏មិនមានផលប្រយោជន៍យុត្តិធម៌ដែលត្រូវផ្តល់ជូនសហព្រះរាជអាជ្ញា នូវការបញ្ជាក់បំភ្លឺដែលខ្លួនស្នើសុំ។

6. ដោយប្រកាសថា ការបិទសវនាការលើភ័ស្តុតាងនៅក្នុងសំណុំរឿង ០០២/០១ នឹងពុំត្រូវបានពន្យារពេល ដោយរង់ចាំការចេញសេចក្តីសម្រេចលើបណ្តឹងសាទុក្ខភ្លាមៗ ដោយពុំចាំបាច់ពិចារណាទៅលើលទ្ធភាពផលប៉ះពាល់ដល់សិទ្ធិ ដែលអាចកើតមានដោយសារការបិទសវនាការនៅក្នុងពេលជំនុំជម្រះ អង្គជំនុំជម្រះសាលាដំបូងប្រថុយប្រថាននឹងការធ្វើឱ្យប៉ះពាល់ដល់ផលប្រយោជន៍ផ្នែកច្បាប់មួយចំនួនដូចជា៖ ការអនុវត្តសិទ្ធិឱ្យមានប្រសិទ្ធភាព និងមានអត្ថន័យ ក្នុងការប្តឹងសាទុក្ខប្រឆាំងនឹងសេចក្តីសម្រេចលើកទីពីរស្តីពីការបំបែកកិច្ចដំណើរការនីតិវិធី[12] សិទ្ធិរបស់ជនជាប់ចោទក្នុងការទទួលបានការជូនដំណឹងពីបទចោទ និងមានពេលវេលា និងមធ្យោបាយក្នុងការរៀបចំការការពារខ្លួន[13] និងជៀសវាងការខាតបង់ឥតប្រយោជន៍នៃកិច្ចដំណើរការនីតិវិធី។ ដូច្នេះ មានការ

---

ករណីដែលបានលើកឡើង” ដែលបញ្ជាក់ពីអង្គហេតុរៀបចំឡើងដោយតុលាការ សម្រាប់មតិយោបល់របស់តុលាការមួយផ្សេងទៀតលើចំណុចណាមួយនៃច្បាប់។ ដំណើរការបណ្តឹងសាទុក្ខធ្វើឡើងដោយអនុលោមតាមសំណើរបស់តុលាការថ្នាក់ក្រោម តាមសំណើរបស់ភាគី។ ដំណើរការនេះត្រូវបានប្រើប្រាស់ជាច្រើនលើកនៅចំពោះមុខតុលាការអង់គ្លេស និងវែលស៍។ *សូមមើលឧទាហរណ៍* រឿងក្តី *Chambers v. DPP* [2012] EWHC 2157 រឿងក្តី *DPP ទល់នឹង Bayer* [2004] 1 Cr. App. Rep. 493។ ដំណើរការស្រដៀងគ្នានេះក៏ឃើញមាននៅសាធារណរដ្ឋអៀរឡង់ (*សូមមើល តុលាការ (បទប្បញ្ញត្តិបន្ថែម) ច្បាប់ឆ្នាំ ១៩៦១* ផ្នែក 52) ប្រទេសនូវែលសេឡង់ (សង្ខេបកិច្ចដំណើរការនីតិវិធី ច្បាប់ឆ្នាំ ១៩៥៧, ផ្នែក 104; *Radhi ទល់នឹងប៉ូលិស* [2013] NZHC 163) និងប្រទេសអូស្ត្រាលី (*សូមមើល* តុលាការសហព័ន្ធនៃអូស្ត្រាលី ច្បាប់ឆ្នាំ ១៩៧៦, ផ្នែក 26) ។ បន្ថែមពីលើនេះទៀត តុលាការជាតិនៅសហភាពអឺរ៉ុប អាចស្នើសុំការបញ្ជាក់បំភ្លឺលើចំណុចផ្សេងៗនៃច្បាប់សហភាពអឺរ៉ុប ពីតុលាការយុត្តិធម៌អឺរ៉ុប។ *សូមមើល*មាត្រា ២៦៧ នៃសន្ធិសញ្ញាស្តីពីការប្រព្រឹត្តទៅនៃសហភាពអឺរ៉ុប។

[12] *សូមមើល* សេចក្តីសម្រេចលើសំណើរបស់សហព្រះរាជអាជ្ញា សុំការបង្គាប់ជាបន្ទាន់ទៅអង្គជំនុំជម្រះសាលាដំបូង ឱ្យចេញសេចក្តីសម្រេចដែលមានសំអាងហេតុស្តីពីការបំបែកកិច្ចដំណើរការនីតិវិធីក្នុងសំណុំរឿង ០០២ ឯកសារ E163/5/1/13/3 ចុះថ្ងៃទី ៨ ខែ ឧសភា ឆ្នាំ ២០១៣ កថាខណ្ឌ ៥ (“ទោះបីជាភ័ស្តុតាងក្នុងសំណុំរឿង ០០២/០១ ត្រូវបញ្ចប់នៅមុនពេលផុតកំណត់កាលបរិច្ឆេទសម្រាប់ចេញសេចក្តីសម្រេចលើបណ្តឹងសាទុក្ខភ្លាមៗជាយថាហេតុនោះក៏ដោយ ក៏ការប៉ះពាល់ដល់សិទ្ធិណាមួយដែលអាចកើតចេញពីកំហុសណាមួយនោះ តម្រូវឱ្យមានការធ្វើអន្តរាគមន៍ និងការពិនិត្យពិច័យលើបណ្តឹងសាទុក្ខ តាមការចាំបាច់ ឬទៅតាមកាលៈទេសៈសមស្រប”។ *សូមមើលផងដែរ* តុលាការសិទ្ធិមនុស្សអឺរ៉ុប(ECtHR) រឿងក្តី *Airey ទល់នឹង* អៀរឡង់ សំណុំរឿងលេខ 6289/73, សាលក្រម ចុះថ្ងៃទី ៩ ខែ តុលា ឆ្នាំ ១៩៧៩ កថាខណ្ឌ ២៤៖ (“អនុសញ្ញានេះមានបំណងធានាឱ្យមានសិទ្ធិដែលមិនមែនត្រឹមតែជាទ្រឹស្តី ឬជាការបំភ័ន្ត ប៉ុន្តែជាសិទ្ធិដែលមានជាក់ស្តែង និងមានប្រសិទ្ធភាព”)។

[13] *សូមមើល* មាត្រា ១៤(៣) នៃកតិកាសញ្ញាស្តីពីសិទ្ធិពលរដ្ឋនិងនយោបាយ(“ក្នុងការសម្រេចលើបទចោទណាមួយលើជនណាមួយនោះ ជននោះត្រូវមានសិទ្ធិទទួលបានការធានាជាអប្បបរមាដូចខាងក្រោម ដោយស្មើៗគ្នាទាំងស្រុង: ក) ត្រូវទទួលបានការជូនដំណឹងយ៉ាងឆាប់រហ័ស និងលម្អិតទៅតាមភាសា ដែលជននោះអាចយល់ពីលក្ខណៈ និងមូលហេតុនៃបទចោទមកលើខ្លួន ខ)

បារម្ភក្នុងការធានាបាននូវសច្ចភាពផ្នែកច្បាប់ដល់ភាគីទាំងអស់ និងធានាថាកិច្ចដំណើរការនីតិវិធីនៅក្នុងសំណុំរឿង ០០២ ត្រូវដំណើរការឱ្យបានលឿន និងមានប្រសិទ្ធផលតាមដែលអាចធ្វើទៅបាន[14]នោះ អង្គជំនុំជម្រះតុលាការកំពូល យល់ឃើញថា នៅក្នុងករណីបច្ចុប្បន្ននេះ គឺមានផលប្រយោជន៍យុត្តិធម៌ដែលត្រូវផ្តល់ជូនសហព្រះរាជអាជ្ញានូវការបញ្ជាក់បំភ្លឺ ដែលខ្លួនស្នើសុំ។

7. កម្រងឯកសារច្បាប់របស់ អ.វ.ត.ក ឆ្លុះបញ្ចាំងពីកិច្ចដំណើរការតាមលំដាប់លំដោយដែលសមហេតុផល និងមានបទដ្ឋាននៅក្នុងកិច្ចដំណើរការជំនុំជម្រះក្តី គឺ៖ (i) ភាគីទាំងឡាយបង្ហាញភស្តុតាងដែលត្រូវពិភាក្សាដេញដោលនៅក្នុងកិច្ចដំណើរការនីតិវិធីជំនុំជម្រះក្តី[15] (ii) ក្រោយចប់កិច្ចពិភាក្សាដេញដោលនេះ ភាគីទាំងឡាយធ្វើសេចក្តីសន្និដ្ឋាន[16] ហើយ (iii) ក្រោយពីចប់ការធ្វើសេចក្តីសន្និដ្ឋានទាំងនោះ ចៅក្រមជំនុំជម្រះ ធ្វើការពិភាក្សាសម្រេច[17]។ នៅក្នុងដំណាក់កាលចុងក្រោយនេះ ភាគីទាំងឡាយ មិនអាចលើកសំណើ ឬចម្លើយសំណើរបន្ថែមទៀតឡើយ[18]។ របៀបរៀបចំកិច្ចដំណើរការស្រដៀងនេះត្រូវបានអនុវត្តនៅថ្នាក់អន្តរជាតិ[19]។

---

ត្រូវទទួលបានពេលវេលាគ្រប់គ្រាន់ និងមធ្យោបាយនៃការការពារខ្លួន")។ *សូមមើល អានុភាពដូចគ្នា* មាត្រា ៣៥ថ្មី នៃច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (អ.វ.ត.ក) ។

[14] *សូមមើល ដូចជា* វិធាន ២១(៤)នៃវិធានផ្ទៃក្នុង ច្បាស់ជាងនេះ សេចក្តីព្រួយបារម្ភលើកឡើងដោយអង្គជំនុំជម្រះសាលាដំបូងនៅក្នុងសេចក្តីសម្រេចលើកទីពីរលើការបំបែកកិច្ចដំណើរការនីតិវិធី កថាខណ្ឌ ១២៦-១៣៤។ *សូមមើលផងដែរ* សេចក្តីសម្រេចលើបណ្តឹងសាទុក្ខភ្លាមៗរបស់សហព្រះរាជអាជ្ញាប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងស្តីពីវិសាលភាព នៃសំណុំរឿងលេខ ០០២/០១ ឯកសារ E163/5/1/13 ចុះថ្ងៃទី ៨ ខែ កុម្ភៈ ឆ្នាំ ២០១៣ កថាខណ្ឌ ៥១។

[15] មាត្រា ៣៣៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌ (រហូតទល់នឹងការបិទកិច្ចពិភាក្សាដេញដោល ជនជាប់ចោទ ដើមបណ្តឹងរដ្ឋប្បវេណី និងអ្នកទទួលខុសត្រូវរដ្ឋប្បវេណី អាចធ្វើសេចក្តីសន្និដ្ឋានជាលាយលក្ខណ៍អក្សរ និងជូនលិខិតស្នាមទាំងអស់ដែលខ្លួនយល់ថាមានប្រយោជន៍ដល់ការសំដែងឱ្យឃើញការពិត [...]")។

[16] មាត្រា ៣៣៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ("ក្រោយកិច្ចពិភាក្សាដេញដោល ប្រធានសវនាការបើកឱ្យជនខាងក្រោមនេះ និយាយជាបន្តបន្ទាប់គ្នា៖ ដើមបណ្តឹងរដ្ឋប្បវេណី អ្នកទទួលខុសត្រូវរដ្ឋប្បវេណី និងជនជាប់ចោទ អាចធ្វើកំណត់សំគាល់ខ្លីៗ-មេធាវីរបស់ដើមបណ្តឹងរដ្ឋប្បវេណី ដើម្បីធ្វើសេចក្តីសន្និដ្ឋានការពារ - ព្រះរាជអាជ្ញា ដើម្បីធ្វើសេចក្តីសន្និដ្ឋានសុំប្តឹង - មេធាវីរបស់អ្នកទទួលខុសត្រូវរដ្ឋប្បវេណី មេធាវីរបស់ជនជាប់ចោទ ដើម្បីធ្វើសេចក្តីសន្និដ្ឋានការពារ [...]")។

[17] មាត្រា ៣៣៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ("តុលាការថយខ្លួនចូលទៅក្នុងបន្ទប់ពិភាក្សាសម្រេច[...]")។

[18] មាត្រា ៣៣៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌ("តុលាការថយខ្លួនចូលទៅក្នុងបន្ទប់ពិភាក្សាសម្រេច។ គ្មានចម្លើយសំណើណាមួយអាចត្រូវបានលើកយកមកសំអាងទៀតបានឡើយ")។

[19] ការអនុវត្តរបស់សាលាក្តីអន្តរជាតិមួយចំនួនគឺត្រូវបិទសវនាការ បន្ទាប់ពីភាគីទាំងពីរបានបញ្ចប់ការបង្ហាញចម្លើយសំណើរៀងៗខ្លួន។ នៅពេលដែលកិច្ចដំណើរការនីតិវិធីត្រូវបានបញ្ចប់ អង្គជំនុំជម្រះសាលាដំបូងធ្វើការពិភាក្សាសម្រេចដោយសម្ងាត់ ហើយមិនទទួលយកភស្តុតាងថ្មីនៅក្នុងដំណាក់កាលពិភាក្សាសម្រេចនេះឡើយ។ *សូមមើល* វិធាន ៨៧ នៃវិធានស្តីពីនីតិវិធី និងភស្តុតាងរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតយូហ្គោស្លាវី វិធាន ៨៧ នៃវិធានស្តីពីនីតិវិធី និងភស្តុតាងរបស់តុលាការព្រហ្ម

8. វិធាន ៩៦(២) នៃវិធានផ្ទៃក្នុងចែងយ៉ាងច្បាស់ថា អង្គជំនុំជម្រះសាលាដំបូងអាចបើកកិច្ចដំណើរការនីតិវិធីឡើងវិញនៅក្នុងដំណាក់កាលពិភាក្សាសម្រេច។ វិធាននេះក៏ត្រូវអនុវត្តទៅលើកិច្ចដំណើរការនីតិវិធីនៅចំពោះមុខអង្គជំនុំជម្រះតុលាការកំពូលផងដែរ[20]។ ការផ្តល់យុត្តិកម្មសម្រាប់ឆន្ទានុសិទ្ធិនេះ គឺមានពីរផ្នែក។ ខាងទិដ្ឋភាពនៃនីតិវិធី តុលាការមិនជាប់កាតព្វកិច្ចជាមួយនឹងសេចក្តីសម្រេចរបស់ខ្លួនស្តីពីកិច្ចរៀបចំសំណុំរឿងឡើយ ដូច្នេះហើយ អាចពិចារណាឡើងវិញទៅលើសេចក្តីសម្រេចទាំងនោះ ដរាបណាការធ្វើដូច្នេះ មិនផ្ទុយទៅនឹងផលប្រយោជន៍យុត្តិធម៌។ ខាងទិដ្ឋភាពនៃការអនុវត្តជាក់ស្តែង តុលាការគួរបើកកិច្ចដំណើរការនីតិវិធីឡើងវិញ នៅពេលដែលខ្លួនរកឃើញថា បញ្ហាពាក់ព័ន្ធនឹងលទ្ធផលនៃការពិភាក្សាសម្រេចតម្រូវឱ្យធ្វើដូច្នេះ។ លទ្ធភាពបើកកិច្ចដំណើរការនីតិវិធីនៃភស្តុតាងឡើងវិញដែលរួមបញ្ចូលដំណាក់កាលពិភាក្សាសម្រេច ក៏ត្រូវបានបញ្ជាក់ផងដែរ ដោយតុលាការព្រហ្មទណ្ឌអន្តរជាតិ *ពិសេស*[21]។

---

ទណ្ឌអន្តរជាតិសម្រាប់រវ៉ាន់ដា (ICTR) វិធាន ១៤៧ នៃវិធានស្តីពីនីតិវិធី និងភស្តុតាងរបស់សាលាក្តីពិសេសសម្រាប់លីបង់ (STL) វិធាន ១៤១ និង ១៤២ នៃវិធានស្តីពីនីតិវិធី និងភស្តុតាងរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិ(ICC) និងវិធាន ៨៧ នៃវិធានស្តីពីនីតិវិធី និងភស្តុតាងរបស់សាលាក្តីពិសេសសម្រាប់ស៊ីរ៉ាឡេអូន(“SCSL”)។

[20] វិធាន ១០៤ *ស្ទួន* នៃវិធានផ្ទៃក្នុង ចែងថា “រាល់វិធានដែលត្រូវអនុវត្តនៅអង្គជំនុំជម្រះសាលាដំបូង ត្រូវយកអនុវត្តចំពោះអង្គជំនុំជម្រះតុលាការកំពូល ក្នុងករណីសមស្រប ប្រសិនបើគ្មានបទប្បញ្ញត្តិដោយឡែកណាមួយនោះទេ”។

[21] រឿងក្តី រដ្ឋអាជ្ញា *ទល់នឹង André Ntagerura, Emmanuel Bagambiki និង Samuel Imanishimwe*, សំណុំរឿងលេខ ICTR-99-46-A, សាលក្រមចុះថ្ងៃទី ៧ ខែ កក្កដា ឆ្នាំ ២០០៦ កថាខណ្ឌ ៥៥ (“ក្នុងសំណុំរឿងបច្ចុប្បន្នអង្គជំនុំជម្រះតុលាការកំពូល ពិចារណាឃើញថា នៅពេលដែលអង្គជំនុំជម្រះសាលាដំបូងសម្រេចធ្វើការពិចារណាឡើងវិញលើសេចក្តីសម្រេចមុនពេលជំនុំជម្រះ ទាក់ទងនឹងភាពជាក់លាក់នៃដីកាបញ្ជូនរឿងទៅជំនុំជម្រះ នៅដំណាក់កាលពិភាក្សាសម្រេច អង្គជំនុំជម្រះសាលាដំបូង គប្បីបង្អាក់ដំណើរការពិភាក្សាសម្រេច ហើយធ្វើការបើកសវនាការឡើងវិញ”)។ *សូមមើលផងដែរ* នូវទស្សនៈដូចគ្នា ប៉ុន្តែមិនជាប់ពាក់ព័ន្ធផ្ទាល់លើចំណុចនេះ០: *រឿងក្តី រដ្ឋអាជ្ញា ទល់នឹង Mićo Stanišić និង Stojan Župljanin សំណុំរឿងលេខ* IT-08-91-T សេចក្តីសម្រេចទទួលយកញត្តិរបស់ Župljanin Motion សុំបើកសវនាការដេញដោលឡើងវិញលើទឡ្ហីករណ៍របស់ក្រុមការពារក្តី ចុះថ្ងៃទី ៣ ខែ មេសា ឆ្នាំ ២០១២ កថាខណ្ឌ ៥-៦ ("ក្រុមការពារក្តី អាចស្នើសុំបង្ហាញភស្តុតាងថ្មី ដោយបើកសវនាការដេញដោលឡើងវិញលើទឡ្ហីករណ៍របស់ខ្លួន។ [...] អង្គជំនុំជម្រះណាមួយអាចអនុវត្តឆន្ទានុសិទ្ធិរបស់ខ្លួន និងកំណត់ ថាតើភស្តុតាងនោះគួរទទួលយក ដែរ ឬយ៉ាងណា”)។ *រឿងក្តី រដ្ឋអាជ្ញា ទល់នឹង Ante Gotovina, Ivan Čermak និង Mladen Markač* សំណុំរឿងលេខ IT-06-90-AR73.6 សេចក្តីសម្រេចលើបណ្តឹងសាទុក្ខបន្ទាន់បង្វិលរបស់ Ivan Čermak និង Mladen Markač ជំទាស់នឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង ក្នុងការបើកសវនាការដេញដោលឡើងវិញលើទឡ្ហីករណ៍របស់រដ្ឋអាជ្ញា ចុះថ្ងៃទី ១ ខែ កក្កដា ឆ្នាំ ២០១០ កថាខណ្ឌ ៥ (“មានមូលដ្ឋានរឹងមាំនៅក្នុងយុត្តិសាស្ត្ររបស់សាលាក្តី ដែលថា បញ្ហាទាក់ទងនឹងការគ្រប់គ្រងកិច្ចដំណើរការនីតិវិធីជំនុំជម្រះ ស្ថិតនៅក្រោមឆន្ទានុសិទ្ធិរបស់អង្គជំនុំជម្រះសាលាដំបូង។ សេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង ដែលអនុញ្ញាតឱ្យបើកសវនាការដេញដោលឡើងវិញលើទឡ្ហីករណ៍របស់រដ្ឋអាជ្ញា គឺជាសេចក្តីសម្រេចមួយដែលមានឆន្ទានុសិទ្ធិបែបនោះ ហើយអង្គជំនុំជម្រះសាលាឧទ្ធរណ៍ត្រូវតែ

9. ការបើកសវនាការលើភស្តុតាងឡើងវិញនឹងត្រូវធ្វើឡើងដោយខានមិនបាន ប្រសិនបើការបំបែកកិច្ចដំណើរការនីតិវិធីត្រូវលុបចោលជាថ្មីម្តងទៀត ឬវិសាលភាពនៃសំណុំរឿង ០០២/០១ នឹងត្រូវពង្រីកបន្ថែមដោយសារលទ្ធផលនៃសេចក្តីសម្រេចលើបណ្តឹងសាទុក្ខ។ ទោះបីជា សេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងដែលមិនបង្អង់កិច្ចដំណើរការនីតិវិធី ដើម្បីរង់ចាំសេចក្តីសម្រេចលើបណ្តឹងសាទុក្ខទាក់ទងនឹងវិសាលភាពនៃការជំនុំជម្រះ មានភាពសមហេតុផល[22]ក៏ដោយ អ្វីដែលចាំបាច់នឹងត្រូវធ្វើការពិចារណានោះ គឺថាតើសមស្រប ដែរ ឬយ៉ាងណា ការដែលឱ្យភាគីធ្វើសេចក្តីសន្និដ្ឋានបិទកិច្ចពិភាក្សាដេញដោល នៅក្នុងស្ថានភាពមួយដែលវិសាលភាពនៃអង្គហេតុចោទប្រកាន់ និងបទចោទនៅក្នុងសំណុំរឿង ០០២/០១ ពុំត្រូវបានដោះស្រាយច្បាស់លាស់នៅឡើយនោះ។ ទោះបីជាមានជម្រើសក្នុងការបើកសវនាការលើភស្តុតាងឡើងវិញក៏ដោយ ក៏អង្គជំនុំជម្រះតុលាការកំពូលពិចារណាឃើញថា ជាបញ្ហាទូទៅ មេធាវីការពារក្តី ពុំត្រូវបានបង្ខំឱ្យធ្វើបទបង្ហាញអំពីទឡ្ហីករណ៍ចុងក្រោយរបស់ខ្លួន មុនពេលដឹងពីវិសាលភាពនៃការជំនុំជម្រះ[23]។ លើសពីនេះទៀត វាជាការឆាប់

---

គោរព"។ (ឯកសារយោងផ្ទៃក្នុងត្រូវបានលុបចោល)។ *រឿងក្តីរដ្ឋអាជ្ញា ទល់នឹង Zejnil Delalić, Zdravko Mucić, Hazim Delić និង Esad Landžo* សំណុំរឿងលេខ IT- 96-21-T សេចក្តីសម្រេចលើសំណើជំនួសរបស់រដ្ឋអាជ្ញាសុំបើកសវនាការដេញដោលលើទឡ្ហីករណ៍របស់រដ្ឋអាជ្ញា ចុះថ្ងៃទី ១៩ ខែ សីហា ឆ្នាំ ១៩៩៨ កថាខណ្ឌ ១៩៩៨ កថាខណ្ឌ ២៧ ("អង្គជំនុំជម្រះសាលាដំបូងត្រូវតែប្រុងប្រយ័ត្នយ៉ាងយកចិត្តទុកដាក់ ដើម្បីកុំឱ្យមានភាពអយុត្តិធម៌កើតឡើងចំពោះជនជាប់ចោទ ដូច្នេះហើយនៅក្នុងកាលៈទេសពិសេសក្នុងករណីដែលយុត្តិធម៌នៃសំណុំរឿងទាមទារឱ្យអង្គជំនុំជម្រះសាលាដំបូង អនុវត្តឆន្ទានុសិទ្ធិរបស់ខ្លួនអនុញ្ញាតឱ្យរដ្ឋអាជ្ញា លើកឡើងភស្តុតាងថ្មីបន្ទាប់ពីភាគីនៅក្នុងការជំនុំជម្រះក្តីព្រហ្មទណ្ឌ បានបញ្ចប់ការលើកឡើងទឡ្ហីករណ៍របស់ខ្លួន") *ត្រូវបានយកស្របដោយឯកភាពនៅក្នុងរឿងក្តីរដ្ឋអាជ្ញា ទល់នឹង Zejnil Delalić, Zdravko Mucić, Hazim Delić និង Esad Landžo សំណុំរឿង* IT- 96-21-A សាលក្រម ចុះថ្ងៃទី ២០ ខែ កុម្ភៈ ឆ្នាំ ២០០១ កថាខណ្ឌ ២៨៨។

[22] យោងតាមវិធាន ១០៤(កថាខណ្ឌចុងក្រោយ) នៃវិធានផ្ទៃក្នុង "លើកលែងតែមានចែងក្នុងវិធានផ្ទៃក្នុង ឬការសម្រេចផ្សេងដោយអង្គជំនុំជម្រះសាលាដំបូង បណ្តឹងសាទុក្ខភ្លាមៗមិនមានអានុភាពបង្អង់នីតិវិធីមុខអង្គជំនុំជម្រះសាលាដំបូងទេ"។

[23] សម្រាប់ការវិភាគលម្អិតអំពីសិទ្ធិរបស់ជនជាប់ចោទក្នុងការទទួលបានការជូនដំណឹងពីបទចោទ, *សូមមើល* អ្នកនិពន្ធ Stefan TRECHSEL, *សិទ្ធិមនុស្សក្នុងកិច្ចដំណើរនីតិវិធីព្រហ្មទណ្ឌ* សាកលវិទ្យាល័យ Oxford, ឆ្នាំ ២០០៥ ទំព័រ ១៩៥ ("នៅពេលដែលព័ត៌មានត្រូវបានធ្វើការទំនាក់ទំនងនោះ បទចោទពុំអាចត្រូវបានកែប្រែឡើយ លើកលែងតែមានការជូនដំណឹងថ្មី និងមានពេលវេលាគ្រប់គ្រាន់ក្នុងការអនុញ្ញាតឱ្យមេធាវីការពារក្តីអាចសម្របសម្រួលទៅតាមស្ថានភាពថ្មីនេះ។ គោលការណ៍នេះ ត្រូវបានស្គាល់ថាជា'គោលការណ៍ស្តីពីភាពមិនអាចផ្លាស់ប្តូរបាន'") ។ *សូមមើលផងដែរ:* តុលាការអឺរ៉ុបស្តីពីសិទ្ធិមនុស្ស (ECtHR), រឿងក្តី *Pélissier និង Sassy ទល់នឹង France*, សំណើសុំលេខ 25944/94 សាលក្រម ចុះថ្ងៃទី ២៥ ខែ មីនា ឆ្នាំ ១៩៩៩ កថាខណ្ឌ ៥២ ("តុលាការពិចារណាឃើញថា ក្នុងបញ្ហាព្រហ្មទណ្ឌ ការផ្តល់ព័ត៌មានទាំងស្រុង និងលម្អិតទាក់ទងនឹងបទចោទប្រឆាំងនឹងជនជាប់ចោទ និងជាលទ្ធផល ការកំណត់តាមផ្នែកច្បាប់ ដែលតុលាការអាចនឹងធ្វើឡើងនោះ គឺជាតម្រូវការចាំបាច់ដើម្បីធានាបានថា កិច្ចដំណើរការនីតិវិធីប្រព្រឹត្តទៅប្រកបដោយយុត្តិធម៌")។

ពេកទាក់ទងនឹងយុត្តិសាស្ត្រនៃកិច្ចដំណើរការនីតិវិធី និងផលចំណេញនៃកិច្ចដំណើរការនីតិវិធី ដែលបង្ខំភាគីឱ្យធ្វើដូច្នេះឡើយ។

10. ទោះបីជានិយាយបែបនេះក៏ដោយ អង្គជំនុំជម្រះតុលាការកំពូលពិចារណាឃើញថា នៅដំណាក់កាលនេះ បញ្ហាទាំងនេះនៅតែជាសម្មតិកម្មនៅឡើយទេ។និយាយឱ្យជាក់ស្តែង ការព្យាករណ៍[24] របស់អង្គជំនុំជម្រះសាលាដំបូងបង្ហាញថា សេចក្តីសម្រេចរបស់អង្គជំនុំជម្រះតុលាការកំពូលលើបណ្តឹងសាទុក្ខភ្លាមៗ ទំនងជានឹងត្រូវចេញមុនពេលដែលសំណុំរឿង ០០២/០១ ឈានដល់ដំណាក់កាលពិភាក្សាសម្រេច[25]។ ដោយដឹងថា កាលបរិច្ឆេទ[26]នៃការជំនុំជម្រះ ពុំទាន់បានកំណត់ច្បាស់លាស់ និងដោយដឹងថា អនុស្សរណៈរបស់អង្គជំនុំជម្រះសាលាដំបូង ពុំបានបង្ហាញជាចាំបាច់ថា អង្គជំនុំជម្រះ នឹងស្នើសុំការដាក់សារណាបិទកិច្ចពិភាក្សាដេញដោលភ្លាមៗ បន្ទាប់ពីការបញ្ចប់នូវការពិនិត្យភ័ស្តុតាងដែលបច្ចុប្បន្នខ្លួនបានជ្រើសរើស ទាក់ទងនឹងវិសាលភាពនៃបទចោទឡើយ។ ហេតុដូច្នេះ ការប៉ះពាល់ដល់សិទ្ធិដែលបានពិភាក្សាខាងលើ អាចត្រូវបានជៀសវាង តាមរយៈការរៀបចំការជំនុំជម្រះដ៏សមស្របមួយ ដូចជា តាមរយៈការរង់ចាំលទ្ធផលនៃបណ្តឹងសាទុក្ខ មុននឹងធ្វើការស្នើឱ្យភាគីដាក់សារណាបិទកិច្ចពិភាក្សាដេញដោល។

11. បញ្ហាពាក់ព័ន្ធមួយដែលបង្ហាញនៅក្នុងសំណើរបស់សហព្រះរាជអាជ្ញានោះ គឺថាតើ ប្រសិនបើច្បាស់លាស់ថា ការអនុវត្តសេចក្តីសម្រេចដែលរងការជំទាស់របស់អង្គជំនុំជម្រះសាលាដំបូង ដែលស្ថិតក្រោមការត្រួតពិនិត្យរបស់តុលាការថ្នាក់លើ បានធ្វើឱ្យប៉ះពាល់ដល់សិទ្ធិរបស់ភាគីនោះ អង្គជំនុំជម្រះតុលាការកំពូល ជាចុងក្រោយ អាចពិចារណាបង្គាប់ឱ្យមានវិធានការសមស្របបណ្តោះអាសន្ន ដោយបង្អង់នូវអានុភាពនៃសេចក្តីសម្រេចដែលរងការជំទាស់នេះ ដែរ ឬយ៉ាងណា។ ទាក់

[24] សូមមើល អនុស្សរណៈរបស់អង្គជំនុំជម្រះសាលាដំបូង(ដែលលើកឡើង នៅពេលដាក់សំណើ ការបិទសវនាការលើភ័ស្តុតាងនៅចុង ខែ មិថុនា ឆ្នាំ ២០១៣ ដែលបន្ទាប់មកភាគីមានរយៈពេលមួយខែសម្រាប់ដាក់សារណាបញ្ចប់របស់ខ្លួន ហើយកាលបរិច្ឆេទសម្រាប់សវនាការលើបទបង្ហាញនៃសេចក្តីសន្និដ្ឋានបិទសវនាការមួយខែក្រោយមកទៀត)។

[25] វិធាន ១០៨ (៤) *ស្ទួន* នៃវិធានផ្ទៃក្នុង អនុញ្ញាតឱ្យមានកាលបិរច្ឆេទកំណត់រយៈពេល ៣ ខែ ដើម្បីឱ្យអង្គជំនុំជម្រះតុលាការកំពូលចេញសេចក្តីសម្រេចលើបណ្តឹងសាទុក្ខភ្លាមៗ ដោយមានលទ្ធភាពពន្យារពេលបាន ១ ខែថែមទៀត "ក្នុងករណីពិសេស"។

[26] កាលបរិច្ឆេទត្រូវបានធ្វើបច្ចុប្បន្នភាពនាពេលថ្មីៗនេះ ដោយបញ្ជាក់ថា សវនាការលើភស្តុតាង នឹងបន្តយ៉ាងហោចណាស់ ក្នុងខែ កក្កដា ដូចដែលអង្គជំនុំជម្រះសាលាដំបូងបានបែងចែករួចរាល់ចំនួន ១៤ ថ្ងៃ សម្រាប់សវនាការពិនិត្យលើឯកសារ និងសួរសំណួរជនជាប់ចោទ គិតចាប់ពីថ្ងៃទី ២៤ ខែ មិថុនា ហើយ អង្គជំនុំជម្រះពុំទាន់បានសម្រេចលើសំណើរបស់ភាគីស្នើសុំសាក្សីបន្ថែម។ សូមមើលអនុស្សរណៈរបស់ចៅក្រម និល នុន ប្រធានអង្គជំនុំជម្រះសាលាដំបូង ចំណងជើងថា "កាលបរិច្ឆេទសម្រាប់ឯកសារចុងក្រោយ និងសវនាការក្នុងសំណុំរឿង ០០២/០១ សម្រាប់សួរសំណួរជនជាប់ចោទ និងសារណាតបទៅនឹងសំណើសុំលេខ E263, E288/1 និង E288/1/1 ចុះថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ ២០១៣ និង ជូនដំណឹងនៅថ្ងៃទី ២១ ខែ មិថុនា ឆ្នាំ ២០១៣"។

00932655



ទងបញ្ហានេះ សូមកត់សម្គាល់ថា កម្រងច្បាប់របស់ អ.វ.ត.ក មិនផ្តល់សិទ្ធិអំណាចច្បាស់លាស់ឱ្យអង្គជំនុំជម្រះតុលាការកំពូល បង្អង់សេចក្តីសម្រេចចាត់របៀបណាមួយដែលបណ្តឹងសាទុក្ខត្រូវបានដាក់ប្តឹងជំទាស់។ ដូចគ្នាដែរ ក្រមនីតិវិធីព្រហ្មទណ្ឌ ពុំបានចែងច្បាស់លាស់ពីបណ្តឹងសាទុក្ខបន្ទាន់បង្ហំ ស្រដៀងនឹងបណ្តឹងសាទុក្ខដូចមានចែងនៅក្នុងវិធានផ្ទៃក្នុងទេ[27] ប៉ុន្តែ ក្រមនីតិវិធីព្រហ្មទណ្ឌចែងពីអានុភាពនៃបណ្តឹងសាទុក្ខមកលើកិច្ចដំណើរការនីតិវិធីជំនុំជម្រះ តែក្នុងករណីពាក់ព័ន្ធនឹងការអនុវត្តសាលក្រមតែប៉ុណ្ណោះ ហើយអនុញ្ញាតឱ្យមានការបង្អង់កិច្ចដំណើរការនីតិវិធីដោយស្វ័យប្រវត្តិ[28]។ ទោះបីជាថាទាក់ទងនឹងចំណុចស្រដៀងគ្នានេះ ក្រមនីតិវិធីព្រហ្មទណ្ឌផ្តល់ការគាំទ្រណាម្យ៉ាងចំពោះការយល់ឃើញដែលថា អង្គជំនុំជម្រះតុលាការកំពូល អាចបង្អង់ការអនុវត្តសេចក្តីសម្រេចណាមួយ ដែលកំពុងត្រូវបានប្តឹងជំទាស់[29] យ៉ាងណាក៏ដោយ ក៏អង្គជំនុំជម្រះតុលាការកំពូលយល់ឃើញថា គប្បីត្រូវស្វែងរកការណែនាំពីមូលដ្ឋាននៃវិធានស្តីពីនីតិវិធីនៅកម្រិតអន្តរជាតិ ដោយហេតុថា វិធានផ្ទៃក្នុងដែលចែងអំពីរបបនៃបណ្តឹងសាទុក្ខនៅ អ.វ.ត.ក គឺកើតចេញពីមូលដ្ឋាននៃវិធានស្តីពីនីតិវិធីទាំងនោះ[30]។

12. វិធានដែលចែងពីនីតិវិធីនៅចំពោះមុខតុលាការព្រហ្មទណ្ឌអន្តរជាតិ ឬតុលាការដែលមានស្តង់ដាអន្តរជាតិ ជារឿយៗផ្តល់អំណាចច្បាស់លាស់ដល់តុលាការកំពូល ឱ្យបង្អង់អានុភាពនៃសេចក្តីសម្រេចណាមួយដែលកំពុងត្រូវប្តឹងជំទាស់[31]។ បន្ថែមពីលើនេះទៀត តុលាការព្រហ្មទណ្ឌទាំងនេះ បានយល់

[27] ក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា ត្រឹមតែចែងពីបណ្តឹងសាទុក្ខភ្លាមៗប្រឆាំងនឹងសេចក្តីសម្រេច ដែល"បញ្ចប់នីតិវិធី"។ *សូមមើល* មាត្រា ៣៨៥។

[28] *សូមមើល មាត្រា ៣៩៨* ក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា ដែលចែងថា "នៅក្នុងរយៈពេលប្តឹងឧទ្ធរណ៍ ការអនុវត្តសាលក្រមត្រូវបង្អង់សិន")។ ស្ថានភាពស្រដៀងគ្នានេះត្រូវបានចែងទាក់ទងនឹងបណ្តឹងសាទុក្ខ ទៅតុលាការកំពូល។ *សូមមើល* មាត្រា ៤២១ និង ៤៣៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា។ ក្រមនីតិវិធីព្រហ្មទណ្ឌអនុញ្ញាតឱ្យបង្អង់កិច្ចដំណើរការនីតិវិធីក្នុងករណីដែល"បញ្ហាបន្ទាន់បង្ហំ"ទាក់ទងនឹង"អញ្ញត្រកម្ម"របស់ភាគីណាមួយត្រូវដោះស្រាយដោយតុលាការមួយទៀត ដែលមានសមត្ថកិច្ចផ្តាច់មុខលើបញ្ហានោះ *សូមមើល*មាត្រា ៣៤២-៣៤៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា។

[29] *សូមមើល* មាត្រា ៣៩៨, ៤៣៥ និង ៣៤២-៣៤៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ដែលត្រូវបានដកស្រង់ខាងលើ។ *សូមមើលផងដែរ* ចំពោះចំណុចស្រដៀងគ្នានេះ មាត្រា ៥៧១(៤)នៃក្រមនីតិវិធីព្រហ្មទណ្ឌបារាំង ដែលអនុញ្ញាតឱ្យបង្អង់កិច្ចដំណើរការជំនុំជម្រះ ឬបណ្តឹងសាទុក្ខខណៈដោយរង់ចាំតុលាការឧទ្ធរណ៍សម្រេចលើបណ្តឹងសាទុក្ខ។

[30] *សូមមើល* មាត្រា ១២(១) នៃកិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជាទាក់ទាងនឹងការកាត់ទោសក្រោមច្បាប់ស្តីពីឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តឡើងក្នុងរបបកម្ពុជាប្រជាធិបតេយ្យ។ មាត្រា ៣៣ (១) ថ្មី នៃច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា(អ.វ.ត.ក)។ វិធាន ២ នៃវិធានផ្ទៃក្នុង។

[31] នៅតុលាការ ICC និង STL បណ្តឹងសាទុក្ខមិនមានអានុភាពឱ្យបង្អង់កិច្ចដំណើរការនីតិវិធីទេ ប្រសិនបើ*អង្គជំនុំជម្រះសាលាឧទ្ធរណ៍* មិនបង្គាប់ឱ្យធ្វើដូច្នេះ (*សូមមើល* មាត្រា ៨២(៣) នៃលក្ខន្តិកៈរបស់តុលាការ ICC) និងវិធាន ១២៦(ច)នៃវិធាន

ឃើញថា នៅក្នុងករណីដែលបទប្បញ្ញត្តិលក្ខន្តិកៈរបស់ខ្លួន មិនចែងពីអំណាចរបស់ខ្លួនឱ្យបានច្បាស់លាស់ ឬឱ្យជាប់ពាក់ព័ន្ធជាសារវន្តក្នុងការសម្រេចលើបញ្ហាណាមួយនោះ[32] តុលាការទាំងនោះមានយុត្តាធិការជាប់រួចជាស្រេចមួយ "ដើម្បីសម្រេចលើបញ្ហាចៃដន្យ ដែលកើតចេញពីលទ្ធផលផ្ទាល់នៃកិច្ចដំណើរការនីតិវិធី ដែលតុលាការទាំងនោះ បានទទួល ដោយផ្តល់សំអាងហេតុថា បញ្ហានោះស្ថិតនៅក្រោមយុត្តាធិការបឋមរបស់ខ្លួន"[33]។ យុត្តាធិការមានជាប់រួចជាស្រេច ត្រូវបានពិពណ៌នាថាជាយុត្តាធិការ"បន្ថែម ឬចៃដន្យក្រៅពីយុត្តាធិការបឋម ហើយត្រូវចាត់ទុកថាជាយុត្តាធិការចាំបាច់ប្រសិនបើមានតម្រូវការចាំបាច់ដើម្បីធានាថាកិច្ចការរដ្ឋបាលតុលាការដំណើរការបានល្អ និងត្រឹមត្រូវយុត្តិធម៌"[34]។ ដូច្នេះ "យុត្តាធិការមានជាប់រួចជាស្រេចនេះ កើតចេញពីពេលដែលបញ្ហាស្ថិតនៅក្រោមយុត្តាធិការបឋមរបស់តុលាការ ត្រូវបានលើកឡើងនៅចំពោះមុខអង្គភាពណាមួយនៃតុលាការនោះ"[35]។ យុត្តាធិការមានជាប់រួចជាស្រេច ត្រូវបានប្រើប្រាស់ *ឧទាហរណ៍ដូចជា* ដើម្បីបង្គាប់ឱ្យមានវិធានការបណ្តោះអាសន្ន[36]។ វិធីសាស្ត្រនេះត្រូវបានអនុវត្តរួចហើយនៅក្នុងយុត្តិ

---

ស្តីពីនីតិវិធី និងភស្តុតាងរបស់តុលាការ STL។ នៅតុលាការ SCSL បណ្តឹងសាទុក្ខបន្ទាន់បង្ខំជំទាស់នឹងសេចក្តីសម្រេចដែលត្រូវបានធ្វើឡើងមុនពេលការបង្ហាញខ្លួនជាលើកដំបូងរបស់ជនជាប់ចោទ គឺមិនបង្អង់កិច្ចដំណើរការនីតិវិធីនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូងឡើយ ប្រសិនបើអង្គជំនុំជម្រះសាលាដំបូង *ឬអង្គជំនុំជម្រះសាលឧទ្ធរណ៍* មិនបង្គាប់ឱ្យធ្វើដូច្នេះ (*សូមមើល* វិធាន ៧២(ជ)នៃ វិធានស្តីពីនីតិវិធី និងភស្តុតាងរបស់តុលាការ SCSL។ បណ្តឹងសាទុក្ខបន្ទាប់បង្ខំជំទាស់លើសេចក្តីសម្រេចដែលត្រូវបានចេញបន្ទាប់ពីការបង្ហាញខ្លួនជាលើកដំបូងរបស់ជនជាប់ចោទ ត្រូវបានអនុញ្ញាតតែក្នុងកាលៈទេសៈពិសេស ហើយមិនមានអនុភាពបង្អង់កិច្ចដំណើរការនីតិវិធីឡើយ ប្រសិនបើអង្គជំនុំជម្រះសាលាដំបូង មិនបង្គាប់ឱ្យធ្វើដូច្នេះ (*សូមមើល* វិធាន ៧៣ (ក) និង(ខ)នៃវិធានស្តីពីនីតិវិធី និងភស្តុតាងរបស់តុលាការ SCSL)។

[32] តុលាការ STL សេចក្តីសម្រេចលើបណ្តឹងសាទុក្ខជំទាស់នឹងដីការបស់ចៅក្រមបុរេជំនុំជម្រះលើយុត្តាធិការ និងសិទ្ធិប្តឹងតវ៉ា សំណុំរឿងលេខ CH/AC/2010/02 អង្គជំនុះជម្រះសាលាឧទ្ធរណ៍ ចុះថ្ងៃទី ១០ ខែ វិច្ឆិកា ឆ្នាំ ២០១០ ("សេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាឧទ្ធរណ៍នៃតុលាការ STL") កថាខណ្ឌ ៤៦ និង ៤៨។

[33] សេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាឧទ្ធរណ៍នៃតុលាការ STL កថាខណ្ឌ ៤៥ ។

[34] សេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាឧទ្ធរណ៍នៃតុលាការ STL កថាខណ្ឌ ៤៥ ។

[35] សេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាឧទ្ធរណ៍នៃតុលាការ STL កថាខណ្ឌ ៤៥ ។

[36] សេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាឧទ្ធរណ៍នៃតុលាការ STL កថាខណ្ឌ ៤៦ *ដោយយោងទៅរឿងក្តីរដ្ឋអាជ្ញា ទល់នឹង Brima និងអ្នកផ្សេងទៀត* សេចក្តីសម្រេចលើបណ្តឹងសាទុក្ខរបស់ក្រុមការពារក្តី ដោយអនុលោមតាមវិធាន ៧៧(ឆ) ស្តីពីការអនុវត្តវិធានការបណ្តោះអាសន្ន និង ដីកា ដោយអនុលោមតាមវិធាន ៧៧(ឆ)(ii) ឯកសារ SCSL-04-16-AR77 ចុះថ្ងៃទី ២៣ ខែ មិថុនា ឆ្នាំ ២០០៥ កថាខណ្ឌ ៩។ តុលាការអឺរ៉ុបស្តីពីសិទ្ធិមនុស្ស (EctHR) *រឿងក្តី* *Mamakutlov* និង *Askarov* *ទល់នឹង* ប្រទេសទួគីសំណុំរឿងលេខ 46827/99 និង 46951/99 សាលក្រម ចុះថ្ងៃទី ៤ ខែ កុម្ភៈ ឆ្នាំ ២០០៥ កថាខណ្ឌ ១២៣-១២៤ និងរឿងក្តី *Veerman* ដីកាចុះថ្ងៃទី ២៨ ខែ តុលា ឆ្នាំ ១៩៥៧ នៅក្នុងសេចក្តីសម្រេចរបស់គណៈកម្មការមជ្ឈត្តករស្តីពីអចលនទ្រព្យ សិទ្ធិ និងផលប្រយោជន៍នៅអាល្លឺម៉ង់ Vol. I (Koblenz, 1958) ទំព័រ ១២០។

00932657



សាស្ត្ររបស់ អ.វ.ត.ក នៅពេលដែល អង្គបុរេជំនុំជម្រះបានប្រើប្រាស់អំណាចមានជាប់រួចជាស្រេចរបស់ខ្លួន ដើម្បីបង្អង់អានុភាពនៃសេចក្តីសម្រេចមួយចេញដោយសហចៅក្រមស៊ើបអង្កេត ខណៈដែលរង់ចាំសេចក្តីសម្រេចលើកិច្ចដំណើរការនីតិវិធីបណ្តឹងសាទុក្ខ ក្នុងគោលបំណងដើម្បីធានាថា សិទ្ធិប្តឹងជំទាស់នឹងមានអត្ថន័យ[37]។ ដូច្នេះ អង្គជំនុំជម្រះតុលាការកំពូលពិចារណាឃើញថា ទាំងនេះគឺស្របតាមមូលដ្ឋាននៃវិធានស្តីពីនីតិវិធីនៅកម្រិតអន្តរជាតិ ហើយក៏មិនផ្ទុយពីក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជាផងដែរ ក្នុងការប្រើប្រាស់អំណាចមានជាប់រួចជាស្រេចរបស់ខ្លួន ដើម្បីបង្អង់ការអនុវត្តលើសេចក្តីសម្រេចលើកទីពីរលើការបំបែកកិច្ចដំណើរការនីតិវិធី ប្រសិនបើចុងក្រោយបំផុតចាំបាច់ត្រូវធានាថា កិច្ចការរដ្ឋបាលតុលាការដំណើរការបានល្អ និងត្រឹមត្រូវយុត្តិធម៌។

[37] ដីកាសម្រេចព្យួរការអនុវត្ត"ដីកាសម្រេចស្តីពីសេចក្តីថ្លែងការណ៍ជាសាធារណៈរបស់សហព្រះរាជអាជ្ញាអន្តរជាតិ ទាក់ទងនឹងសំណុំរឿង ០០៣" ឯកសារ D14/1/2 ចុះថ្ងៃទី ១៣ ខែ មិថុនា ឆ្នាំ ២០១១។

13. យោងតាមសំអាងហេតុដូចខាងលើ **អង្គជំនុំជម្រះតុលាការកំពូលសម្រេចៈ**

**ទទួលយក** សំណើនេះ និង

**ផ្តល់** ការបញ្ជាក់បំភ្លឺខាងផ្លូវច្បាប់ ដូចបានបង្ហាញខាងលើ។

ភ្នំពេញ ថ្ងៃទី ២៦ ខែ មិថុនា ឆ្នាំ ២០១៣

**ប្រធានអង្គជំនុំជម្រះតុលាការកំពូល**

**គង់ ស្រ៊ឹម**